# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1253

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : កិច្ចសម្របសម្រួលផែនការគ្រប់គ្រងគុណភាពទឹកដែលមានលក្ខណៈទូលំទូលាយនៅតំបន់អាងទន្លេមេគង្គតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ និងជំរុញការចូលរួមជាសាធារណៈ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/06/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/06/24 |

៣. ចំណាយគម្រោងសរុប $338,400

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

RESPONSIBLE UNIT — Department of Water Quality Management, General Department of Environmental Protection, Ministry of Environment

អង្គភាពទទួលខុសត្រូវ — នាយកដ្ឋានគ្រប់គ្រងគុណភាពទឹក នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន

៥. ស្ថានភាពគម្រោង — គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

(១)រៀបចំគោលការណ៍ណែនាំ(វិធីសាស្ត្រ) បច្ចេកទេសស្តីពីការកំណត់បន្ទុកបំពុលដែលហូរចូលតំបន់ទឹកសាធារណៈ អាងទន្លេមេគង្គ
(២)ចូលរួមចំណែកក្នុងការពង្រឹងការគ្រប់គ្រងគុណភាពទឹកសាធារណៈ និងសុខភាពសាធារណៈ ប្រកបដោយចីរភាព។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? — មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ព្រៃវែង, ស្ទឹងត្រែង, កណ្តាល, សៀមរាប, ពោធិ៍សាត់, ក្រចេះ, រាជធានីភ្នំពេញ, កំពង់ឆ្នាំង, បាត់ដំបង, កំពង់ធំ, កំពង់ចាម, បន្ទាយមានជ័យ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

(១)ចុះប្រមូលព័ត៌មាន ទិន្នន័យប្រភពបំពុលទឹក និងប្រមូលសំណាកទឹកមកធ្វើការវិភាគនៅមន្ទីរពិសោធន៍ ក្រសួង បរិស្ថាន
(២) សិក្សាវិភាគ ត្រួតពិនិត្យវាយតម្លៃព័ត៌មាន ទិន្នន័យ និងលទ្ធផលវិភាគសំណាកទឹក
(៣) ពិនិត្យលើ ក្របខណ្ឌលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
(៤) រៀបចំកសាងឯកសារគោលការណ៍ណែនាំ (វិធីសាស្រ្ត) បច្ចេកទេស ស្តីពីការកំណត់បន្ទុកបំពុលដែលហូរចូល តំបន់ទឹកសាធារណៈអាងទន្លេមេគង្គ
(៥) ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ និងជម្រុញការចូលរួមជាសាធារណៈ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

នាយកដ្ឋានគ្រប់គ្រងគុណភាពទឹកនឹងចូលរួមជាមួយអ្នកជំនាញការ ដើម្បីប្រមូលទិន្នន័យប្រភពបំពុលរបស់ ក្រុង/ខេត្តគោលដៅ និងរៀបចំសៀវភៅគោលការណ៍ណែនាំបច្ចេកទេសដើម្បីប៉ាន់ប្រមាណបន្ទុកបំពុល។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងផ្តោតទៅលើការសិក្សាបន្ទុកបំពុលដែលហូរចូលក្នុងអាងទន្លេមេគង្គដែលអាចធ្វើឱ្យមានការប៉ះពាល់ ធ្ងន់ធ្ងរដល់បរិស្ថានទឹកក្នុងអាងទន្លេមេគង្គ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

១- ប្រជាជនដែលរស់នៅតាមអាងទន្លេ
២- ប្រជាជនដែលអាស្រ័យផល(ប្រភពអាហារ)ពីអាងទន្លេ
៣- អ្នករៀបចំផែនការគ្រប់គ្រង
៤- អ្នកសិក្សាស្រាវជ្រាវអាចប្រើប្រាស់ទិន្នន័យនេះសម្រាប់ការសិក្សាបន្ត។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះពុំមានផលប៉ះពាល់លើប្រជាជន និងបរិស្ថាននោះទេ ប៉ុន្តែវាពិតជាចូលរួមចំណែកជួយដល់ការកាត់បន្ថយ ភាពក្រីក្រ តាមរយៈការធានាបានសុវត្ថិភាពទឹកបឹងទន្លេសាបមិនទទួលរងការបំពុល ដែលបង្កឱ្យមានផលប៉ះពាល់ដល់ សុខភាពសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១៧. គុណភាពទឹក (ទូទៅ)** | 95 | **ទាក់ទងខ្លាំង** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**តួនាទីរបស់បុរសនិងស្ត្រី ពិតជាមានសារៈសំខាន់ក្នុងការចូលរួមការថែរក្សា ការពារ និងទប់ស្កាត់ការបំពុលទឹក ពិសេសស្ត្រីផ្តល់អាទិភាពក្នុងការចូលរួម តាមរយៈសកម្មភាពបញ្ជ្រាបការអប់រំជាអាថ៌ កុំបោះចោលសំរាម សំណល់រឹង ការហាមឃាត់ចាកសារធាតុគីមីពុលក្នុងទឹក កុំបង្ហូរ ឬ ចាក់សំណល់រាវមានសារជាតុពុលក្នុងទឹក។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មានធនធានមនុស្ស និងសមត្ថភាពជំនាញ និងបទពិសោន៍គ្រប់គ្រាន់ ក្នុងការសហការជាមួយ វិទ្យាស្ថានបច្ចេកវិទ្យា កម្ពុជា និងជំនាញការនៃអង្គការភាពជាដៃគូរបរិស្ថានទឹកក្នុងតំបន់អាស៊ីសម្រាប់អនុវត្តគម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**នេះជាគម្រោងថ្មី និងកំពុងស្វែងរកជំនួយគាំទ្រ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

3

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងស្វែងរកមូលនិធិពីដៃគូរអភិវឌ្ឍនានា។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| ចំណាយប្រតិបត្តិ | 0.0 | 0.0 | 0.0 | 37.8 | 37.8 | 37.8 | 113.4 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 9.5 | 9.5 | 9.5 | 28.5 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 8.3 | 8.3 | 8.3 | 24.9 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 75.0 | 75.0 | 75.0 | 225.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 10.0 | 10.0 | 10.0 | 30.0 | 0.0 |
| ទទួលសម្ភារៈ | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 30.0 | 30.0 | 30.0 | 90.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 15.0 | 15.0 | 15.0 | 45.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 112.8 | 112.8 | 112.8 | 338.4 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 112.8 | 112.8 | 112.8 | 338.4 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: